# sheet

# fact

Khmer

# ស្ត្រីនិងមេរោគ HIV
# រោគសញ្ញា

(Women and HIV - Fact Sheet No 3 - Symptoms)

# 3

March 1997
[NGO-6080]

**fact sheet 3 of 6**

**A series of fact sheets for women about HIV**

**1 Testing**
**2 Newly Diagnosed**
**3 Symptoms**
**4 Treatments**
**5 Preganancy**
**6 Parenting**

សេរីនៃក្រដាសពត៌មានសម្រាប់ស្ត្រី អំពីមេរោគ **HIV** ។

ការធ្វើតេស្ត
ទើបតែរកឃើញថាមានមេរោគ
រោគសញ្ញា
ការព្យាបាល
ផ្ទៃពោះ
ការធ្វើជាមាតាបិតា

***Produced by***
**FPA Health *and* Multicultural HIV/AIDS Service based on material written by FPA Health & AIDS Council of NSW**

**Available from FPA Health**
**Ph: 9716 6099**
**Fax: 9716 6164**
***and***
**MHAS**
**Ph: 9515 3098**
**Fax: 9550 6815**

រហូតមកទល់នឹងពេលនេះ មានការសិក្សាស្រាវជ្រាវតិចតួចណាស់ស្តីអំពីបញ្ហាសុខភាពនិងសេចក្តីត្រូវការចាំបាច់របស់ស្ត្រីដែលមានមេរោគ HIV ។ ហេតុដូច្នេះ អ្វីៗដែលយើងបានដឹងនៅពេលនេះគឺសុទ្ធតែជាការដកស្រង់ពីបទពិសោធន៍របស់ស្ត្រីដែលមានមេរោគផ្ទាល់ ពីវេជ្ជបណ្ឌិតរបស់គេ និងអ្នកថែទាំអ្នកជម្ងឺឯទៀតតែប៉ុណ្ណោះ។ មនុស្សម្នាក់ៗអាចមានប្រតិកម្មប្លែកគ្នាខ្លះៗទៅលើមេរោគ HIV ។ តែមានរោគសញ្ញាជាច្រើនដែលតែងតែកើតមានឡើងចំពោះអ្នកមានមេរោគ HIV ភាគច្រើន ដូចជាការបែកញើសនៅពេលយប់ មានជម្ងឺសើស្បែកបណ្តាលដោយជាតិផ្សិតជាដើម។ មានរោគសញ្ញាដទៃទៀតដែលតែងតែកើតមានលើរូបស្ត្រីជាទូទៅ។ ប័ណ្ណពត៌មាននេះនឹងធ្វើការពិភាក្សាអំពីរោគសញ្ញា ដែលគេតែងជួបប្រទះជាទូទៅ ក៏ប៉ុន្តែគួរចងចាំថា មិនមែនគ្រប់រូបស្ត្រីអាចជួបប្រទះរោគសញ្ញាទាំងអស់នោះឡើយ។ ជាការសំខាន់គឺត្រូវទៅជួបវេជ្ជបណ្ឌិតមានការពិសោធន៍ខាងរោគ HIV នេះ ដើម្បីជួយការពារនិងព្យាបាលអ្នក។

បើតាមអត្ថន័យខាងការពិនិត្យជម្ងឺ HIV ជាជម្ងឺមួយដែលរាលដាលតាំងពីដំណាក់គ្មានរោគសញ្ញា ទៅដល់ដំណាក់មានរោគសញ្ញា។ គឺពីដំណាក់គ្មានឃើញការឈឺចាប់ធ្វើទុក្ខអ្វីសោះ ទៅដល់ដំណាក់ធ្ងន់បន្តិចម្តងៗ រហូតដល់ពេលគេហៅថាមានជម្ងឺអេដស៍។ ការឈឺចាប់ភាគច្រើនអាចការពារនិងព្យាបាលបាន។

តាមការពិត មនុស្សមានមេរោគ HIV តិចតួចណាស់ដែលឈឺតាមលំដាប់ថ្នាក់ច្បាស់លាស់ដូច្នេះ។ អ្នកខ្លះមានរោគសញ្ញាដូចជម្ងឺអេដស៍បេះបិទតែម្តងគត់ រួចក៏បាត់ទៅវិញជាច្រើនឆ្នាំក៏មាន។ រោគសញ្ញាទាំងនោះអាចបាត់ មាន ធ្ងន់ស្រាលប្លែកៗគ្នា។

ការចាប់ផ្តើមមានដំបៅក្លាយជាសញ្ញាបង្ហាញថា ប្រព័ន្ធការពារខ្លួនរបស់អ្នកជម្ងឺចុះខ្សោយ មិនអាចប្រយុទ្ធបាក់តេរីឬវីរុសក្នុងខ្លួនបាន។ ចំពោះស្ត្រីដែលមានមេរោគ HIV ការចុះអន់ខ្សោយប្រព័ន្ធការពារអាចបណ្តាលឲ្យមានដំបៅនៅក្នុងមាត់ ក្រពះ ស្បូត រន្ធយោនី យោនី រន្ធគូថ ឬសើស្បែក។ ដំបៅទាំងនោះអាចព្យាបាលឲ្យជាបាន។

សូមពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នក អំពីវិធីការពារព្យាបាលសម្រាប់ការពារជួយកុំឲ្យមានដំបៅដែលបណ្តាលមកពីការកើតមានមេរោគ HIV នោះ។ វេជ្ជបណ្ឌិតរបស់អ្នកគួរតែធ្វើតេស្តដើម្បីវាស់កម្រិតប្រព័ន្ធការពារខ្លួនរបស់អ្នកឲ្យបានទៀងទាត់ ដើម្បីឲ្យបានដឹងថា ពេលណាអ្នកត្រូវធ្វើការព្យាបាលឲ្យមានប្រសិទ្ធភាព។ ការវាស់កម្រិតប្រព័ន្ធការពារ ធ្វើឡើងដោយការរាប់ចំនួនកោសិកា CD4 (ឬកោសិកា T) ហើយនិងការធ្វើតេស្តវាស់កំរិតវីរុស (viral load test)។ គេត្រូវចាក់យកឈាមគំរូពីអ្នក ដើម្បីធ្វើតេស្តទាំងពីរនេះ។

ការរាប់កោសិកា CD4 នេះ គឺដើម្បីប្រមាណមើលពីប្រព័ន្ធការពារសុខភាពអ្នក និងការខូចខាតដែលមានរួចមកហើយ។ បើចំនួនកោសិកា CD4 ឡើងខ្ពស់ នោះបានន័យថាការខូចខាតមានតិច។ ការធ្វើតេស្តវាស់កំរិតវីរុស គឺធ្វើឡើងដើម្បីឲ្យបានដឹងអំពីចំនួនមេរោគ HIV នៅក្នុងឈាមអ្នក។ ការធ្វើតេស្តនេះនឹងបង្ហាញអំពីសកម្មភាពរបស់វីរុស និងការខូចខាតដែលកំពុងកើតមាននៅលើប្រព័ន្ធការពាររបស់អ្នក។ បើកំរិតវីរុសនេះមានខ្ពស់ នោះការខូចខាតនៅក្នុងប្រព័ន្ធការពារខ្លួនគឺមានច្រើន។

## ការថែរក្សាខ្លួនឯង

ជនភាគច្រើនដែលមានមេរោគ HIV អាចរស់នៅបានយូរឆ្នាំដោយគ្មានរោគសញ្ញាឬជម្ងឺអ្វីឡើយ។ សម័យឥឡូវនេះ វិធីព្យាបាលបានរីកដុះដាលជឿនលឿនគ្រប់ពេល ដោយគេរកឃើញថ្នាំកាន់តែបានសក្តិសិទ្ធិសម្រាប់ទប់ទល់កុំឲ្យមេរោគកើនឡើងនៅក្នុងខ្លួនថែមទៀត។ ព្រមពេលជាមួយគ្នានេះ ផែនការព្យាបាលបន្ថែម ការទទួលទានម្ហូបអាហារល្អៗ ការហាត់ប្រាណ ការទទួលទានដំណេកលក់ ជីវភាពរស់នៅគ្មានព្រួយកង្វល់និងប្រកបដោយសុខភាពល្អ អាចជួយឲ្យប្រព័ន្ធការពារខ្លួនរឹតតែខ្លាំងឡើង។ ការទាំងនេះ នាំឲ្យយើងជំនះនឹងគ្រប់ជម្ងឺរាតត្បាត ហើយអាចបង្កើតឲ្យមានសុខុមាលភាពប្រសើរទៅទៀត។

## រោគសញ្ញា

ស្ត្រីដែលមានមេរោគ HIV អាចជួបប្រទះបញ្ហាសុខភាពផ្លូវភេទនិងជម្ងឺស្ត្រីផ្សេងដូចស្ត្រីដទៃទៀតដែរ។ ការខុសប្លែកដែលអាចកើតមានគឺថា ស្ត្រីមានមេរោគ HIV អាចមានជម្ងឺដំបៅរលាកក្នុងយោនីនិងជម្ងឺកាមរោគជាងធម្មតា ហើយជម្ងឺទាំងនោះច្រើនតែធ្ងន់ធ្ងរហើយក្រជាទៀតផង។ ជារឿយៗ ស្ត្រីទាំងនោះតែងមានជម្ងឺប្រាំងជម្ងឺរលាកក្នុងត្រគាក និងជម្ងឺឬសនៅក្នុងយោនី។ បើគេរកឃើញនិងព្យាបាលទាន់ពេល ជម្ងឺទាំងនោះអាចជាសះស្បើយបានបើមិនដូច្នោះទេវានឹងបង្កឲ្យខូចសុខភាព ហើយមានការលំបាកក្នុងខ្លួនផង។ ជួនកាលស្ត្រីមានមេរោគ HIV ដែលមានរលាកក្នុងយោនី គឺមានការពិបាកច្រើនក្នុងការព្យាបាល។ វេជ្ជបណ្ឌិតរបស់អ្នកគួរតែពិនិត្យឲ្យបានទៀងទាត់និងហ្មត់ចត់ទៅលើជម្ងឺស្ត្រីនិងជម្ងឺដែលគ្មានប្រសិទ្ធភាពតាមរបៀបព្យាបាលធម្មតាទាំងនោះ។

## ការចុះទម្ងន់

គេរកឃើញថា មេរោគ HIV អាចមាននៅតាមស្រទាប់ក្នុងពោះវៀន ហើយវាអាចធ្វើឲ្យរំខានដល់ការស្រូបយកម្ហូបអាហារ។ មេរោគ HIV អាចបណ្តាលឲ្យមានជម្ងឺដំបៅរលាកក្រពះ ហើយនាំឲ្យមានរាគរូសនិងចុះទម្ងន់។ ដើម្បីជាជំនួយ អ្នកគួរពិគ្រោះជាមួយអ្នកឯកទេសខាងម្ហូបអាហារ ដែលមានបទពិសោធន៍ខាងមេរោគ HIV នេះ។ ការរក្សាកុំឲ្យចុះទម្ងន់ ជាពិសេសកុំឲ្យស្រកសាច់ដុំ អាចជួយការពារកុំឲ្យប្រព័ន្ធការពារខ្លួនយើងអន្តរាយខូចខាត ហើយធ្វើកុំឲ្យមេរោគ HIV រាតត្បាតកាន់តែខ្លាំងផង។ ផ្ទាំងសាច់ដុំអាចជួយឲ្យខ្លួនយើងទប់ទល់ជម្ងឺនានាផង ហើយធ្វើឲ្យខ្លួនយើងឆាប់ជាពីជម្ងឺទាំងនោះផង។ សូមពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់អ្នក ឬ/និងអ្នកឯកទេសខាងព្យាបាលបន្ថែម (complementary therapist) អំពីរឿងនេះ។

FPA health

**Funded by NSW Department for Women**

## ការផ្លាស់ប្តូររដូវ

ស្រ្តីដែលមានមេរោគ HIV តែងតែកត់សំគាល់ថា ដំណើររដូវប្រចាំខែ (menstrual cycle) របស់គេមានការប្រែប្រួល ដូចជាមានការធ្លាក់ឈាមជាប់រហូត ធ្លាក់ឈាមម្តងៗ ចុករមួល និងរដូវធ្លាក់ច្រើនលើសធម្មតា។ ស្រ្តីជាច្រើនធ្លាប់មានការពិសោធន៍ថា ការប្រែប្រួលរដូវតែងកើតឡើងនៅពេលចាប់ផ្តើម ឬផ្លាស់ប្តូរកំរិតថ្នាំព្យាបាល។ ការរាំងរដូវអាចជាសញ្ញាប្រាប់ថា កំរិតថ្នាំប្រើហួសកំរិត ដូច្នេះអ្នកគួរសាកសួរគ្រូពេទ្យអ្នកអំពីរឿងនេះ និងអំពីការផ្លាស់ប្តូរឯទៀតដែលអ្នកបានកត់សំគាល់។ ភាពតានតឹងក្នុងចិត្ត ការចុះទម្ងន់ និងការប្រើថ្នាំញៀនចាក់តាមសរសៃ អាចនាំឲ្យមានការផ្លាស់ប្តូររដូវដែរ។ រដូវធ្លាក់ច្រើនលើសពីធម្មតាតែមួយមុខគត់ អាចធ្វើឲ្យស្រ្តីមានមេរោគ HIV បាត់បង់ជាតិដែកច្រើន (នាំឲ្យខ្វះឈាមក្រហម)។ ការបរិភោគអាហារដែលមានជាតិដែកច្រើន និងការលេបថ្នាំមានជាតិដែក អាចជួយកែជម្ងឺនេះបានយ៉ាងងាយ។ ការព្យាបាលដោយថ្នាំរុក្ខជាតិ អាចបានសក្តិសិទ្ធិលើការមានរដូវប្រែប្រួល រួមទាំងការធ្វើទុក្ខមុនពេលមានរដូវ(PMT) និងការឈឺពោះ។ ការលេបថ្នាំបង្ការកូន ក៏អាចជួយត្រួតត្រាជាតិអ័រម៉ូន ហើយធ្វើឲ្យរដូវបានធម្មតាវិញ។ តែទោះជាយ៉ាងណាក្តី ភស្តុតាងខ្លះបានបង្ហាញថា ការលេបថ្នាំបង្ការកូនអាចបណ្តាលឲ្យមេរោគ HIV ស្រក់ចេញទឹកកស្បូន។ នៅពេលណាការនេះកើតឡើង មេរោគ HIV អាចទៅកនៅក្នុងទឹកកស្បូន ហើយបណ្តាលឲ្យគ្រោះថ្នាក់នៃការចំលងមេរោគកាន់តែខ្លាំង។

## ជម្ងឺជ្រាំង (Candidiasis [Thrush])

ជម្ងឺជ្រាំងគឺជាជម្ងឺដែលច្រើនតែកើតឡើងនៅលើរូបស្រ្តីជាច្រើន។ វាបណ្តាលមកពីផ្សិតដំបែដែលតែងតែមានជាធម្មតានៅក្នុងយោនី រន្ធគូថ និងពោះវៀនបានដុះច្រើនពេក។ ចំពោះស្រ្តីដែលមានមេរោគ HIV ការកើតជ្រាំងជាញឹកញយអាចជារោគសញ្ញាដំបូងបង្ហាញថា យើងអាចឆ្លងមេរោគ HIV ហើយបើយើងបណ្តោយទុកវាឲ្យយូរ វាអាចបណ្តាលឲ្យមានបញ្ហាធ្ងន់ធ្ងរ។ រោគសញ្ញានៃការកើតជម្ងឺជ្រាំងគឺការឈឺចាប់និងរមាស់នៅខាងក្នុងនិងខាងក្រៅយោនី ពេលខ្លះមានធ្លាក់សជាដុំសៗ ឬទឹកលាយដុំសៗដូចឈីស (cheese) ពណ៌ស ហើយមានឈឺពោះផង។ រោគសញ្ញានៃការកើតជ្រាំងនៅក្នុងមាត់ គឺមានឈឺបំពង់ក ហើយអណ្តាតឡើងស។ ស្រ្តីដែលមានមេរោគ HIV តែងតែមានជ្រាំងនៅក្នុងមាត់ យោនី និងបំពង់កជាញឹកញាប់ ហើយពិបាកព្យាបាលណាស់។ ការសិក្សាបានបង្ហាញឲ្យឃើញថា ការប្រើថ្នាំការពារឈ្មោះ fluconazole មានប្រសិទ្ធភាពណាស់ ទាំងការពារនិងព្យាបាលជម្ងឺជ្រាំងនេះ។ ជាការសំខាន់គឺនៅពេលចាប់ព្យាបាល ត្រូវព្យាបាលឲ្យបានគ្រប់កំណត់កំរិតរបស់វា។ ជ្រាំងដែលកើតនៅលើកស្បូន ឬទ្វាមាសដែលស្រាលៗ អាចព្យាបាលដោយការប្រើថ្នាំច្របាច់ប្រឆាំងនឹងផ្សិត (anti-fungal cream) ឬថ្នាំគ្រាប់សំរាប់លេបផ្សំដោយជាតិ acidophilus ។ ការស្លៀកសំលៀកបំពាក់ជាតិកប្បាសរលុងៗ ក៏អាចជួយការពារបានដែរ។ ជ្រាំងដែលកើតនៅក្នុងបំពង់អាហារអាចមានន័យថា មានជម្ងឺអេដស៍ ហើយអាចមានគ្រោះថ្នាក់ដល់ជីវិត។ ជម្ងឺនេះត្រូវតែព្យាបាលដោយពេទ្យឯកទេស។

## ជម្ងឺពងទឹក (Herpes)

ជម្ងឺពងទឹកគឺជាក្រុមវីរុសដែលអាចបង្ករឲ្យមានជម្ងឺជាច្រើនមុខ ទោះបីជាអ្នកនោះមានមេរោគ HIV ហើយក៏ដោយ។ ចំពោះជនដែលមានមេរោគ HIV វិញ រោគសញ្ញាដែលទាក់ទងនឹងវីរុស herpes នេះតែងតែធ្ងន់ធ្ងរ ហើយក្រជាទៀតផង។ គេយល់ថា ជម្ងឺពងទឹកអាចមានប្រតិកម្មទៅវិញទៅមកជាមួយមេរោគ HIV ព្រោះថា មេរោគទាំងពីរនេះប្រយុទ្ធទៅលើប្រព័ន្ធការពារខ្លួនយើងដូចគ្នា។ ជម្ងឺពងទឹកដែលគេច្រើនជួបប្រទះរួមមាន:

*ជម្ងឺពងទឹកក្រុម Herpes Simplex I:* នាំឲ្យពងទឹកលើបបូរមាត់ គ្រុនក្តៅ ពងលើបបូរមាត់អាចនៅជាច្រើនថ្ងៃឬច្រើនសប្តាហ៍។ មនុស្សភាគច្រើនតែងបានជួបប្រទះវីរុស herpes simplex ប្រភេទនេះ។

*ជម្ងឺពងទឹកក្រុម Herpes Simplex II (ឬជម្ងឺស្វាយបែក):* នាំឲ្យមានពងទឹកនៅជុំវិញប្រដាប់បន្តពូជនិងរន្ធគូថ។ អ្នកអាចមានការមិនស្រណុកក្នុងខ្លួន ដូចជាមានជម្ងឺគ្រុនផ្តាសាយអញ្ជឹង នៅមុននិងក្នុងពេលមានកើតជម្ងឺនេះ។

*ជម្ងឺរើម (Shingles):* ជម្ងឺមានពងទឹកថ្លាដែលឈឺក្រហាយខ្លាំងនៅលើស្បែក។ ជម្ងឺនេះបណ្តាលមកពីការរើជម្ងឺចាស់ឡើងវិញ ហើយជាសញ្ញាឲ្យដឹងថា មុខងារប្រព័ន្ធការពារក្នុងខ្លួនយើងកំពុងចុះខ្សោយ។

វីរុសនៃជម្ងឺពងទឹក herpes នេះ អាចឆ្លងតាមការប៉ះពាល់ផ្ទាល់តាមផ្លូវភេទ ឬតាមមាត់ទៅលើកន្លែងដែលឈឺ។ ជម្ងឺពងទឹកអាចព្យាបាលដោយថ្នាំឈ្មោះ Zovirax (acyclovir) ។ សូមពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់អ្នកអំពីការព្យាបាល ដើម្បីការពារកុំឲ្យមានជម្ងឺពងទឹកនេះ។ ជាតិស័ង្កសីនិងជីវជាតិ C និង E អាចជួយការពារមិនឲ្យជម្ងឺពងទឹកនេះរើឡើងវិញ។ គេផ្តាំឲ្យអ្នកដែលឧស្សាហ៍មានជម្ងឺនេះទទួលទានអាហារដែលមានវីតាមីន B ជាតិកាល់ស្យូម និងជាតិដែកច្រើន។

## ជម្ងឺរលាកក្នុងត្រគាក (Pelvic Inflammatory Disease [PID])

ជម្ងឺរលាកក្នុងត្រគាកបណ្តាលមកពីជម្ងឺកាមរោគ ដែលមិនបានព្យាបាលឲ្យស្ះស្បើយ ដូចជាជម្ងឺប្រមេះ ឬជម្ងឺក្លាមេឌីយ៉ា (chlamydia) ។ ចំពោះស្រ្តីដែលមានរោគ HIV ជម្ងឺរលាកត្រគាកអាចមិនមែនបណ្តាលមកពីជម្ងឺកាមរោគទេ។ ជម្ងឺនេះកើតមានច្រើនលើស្រ្តីដែលមានមេរោគ HIV ហើយច្រើនតែខ្លាំងក្លាផង។

ស្រ្តីខ្លះអាចមានជម្ងឺ តែមិនដឹងខ្លួនថាមានជម្ងឺនេះទេ គឺគ្រាន់តែមានរោគសញ្ញាខ្លះ ដូចជាឈឺផ្នែកក្រោមចង្កេះនិងពោះ ឈឺនៅពេលរួមដំណេក ឈឺជ្រៅក្នុងត្រគាក ធ្លាក់ឈាមនៅចន្លោះរដូវ មានធ្លាក់ស ក្តៅខ្លួន និងហត់។ ជម្ងឺរលាកត្រគាកដែលមិនបានព្យាបាល អាចនាំឲ្យមានការឈឺចាប់ ហើយអាចបង្កឲ្យលែងមានកូនផង។ សូមត្រួតពិនិត្យសុខភាពផ្ទាល់ខ្លួន ហើយពិគ្រោះជាមួយគ្រូពេទ្យរបស់អ្នក បើអ្នកសង្កេតឃើញមានការប្រែប្រួលឬមានកង្វល់អ្វីមួយ។

## ជម្ងឺមហារីកកស្បូន (Cervical Cancer)

មហារីកកស្បូនគឺជាបញ្ហាសុខភាពដ៏ធំសំបើមមួយសម្រាប់ស្រ្តីអូស្រ្តាលី ហើយបានប៉ះពាល់ស្រ្តីជាច្រើនរៀងរាល់ឆ្នាំ។ មហារីកកស្បូនបណ្តាលមកពីការហើមរីកកោសិកានៅកស្បូន ហើយអាចបណ្តាលឲ្យស្លាប់បាន។ តែជម្ងឺនេះអាចការពារបាន បើគេរកឃើញហើយព្យាបាលទាន់ពេល។ តាមការសង្កេតពេលពិនិត្យជម្ងឺ ស្រ្តីដែលមានមេរោគ HIV អាចមានកោសិកាកស្បូនខុសពីធម្មតាជាងស្រ្តីដែលគ្មានមេរោគនេះ។ កោសិកានោះអាចក្លាយទៅជាមហារីកក្នុងពេលដ៏ឆាប់បំផុត។ កោសិកាទាំងនោះព្យាបាលបានដោយងាយបំផុត បើគេរកវាឃើញទាន់ពេល។ កោសិកាខុសពីធម្មតា (Dysplasia) នោះ អាចកើតមានយ៉ាងឆាប់បំផុតចំពោះស្រ្តីដែលមានកំរិតកោសិកា CD4 តិចជាង 400 ។ នៅឆ្នាំ 1993 មហារីកកស្បូនត្រូវគេដាក់ក្នុងតារាងជម្ងឺដែលទាក់ទងនឹងជម្ងឺអេដស៍ដែរ។

ហេតុដូច្នេះហើយបានជាការធ្វើតេស្តស្បូន (Pap smears) មានសារៈសំខាន់ក្នុងការរកឃើញនិងព្យាបាលជម្ងឺជាប្រញាប់។ គេធ្វើការណែនាំទូទាំងប្រទេសថា ស្រ្តីទាំងអស់ត្រូវធ្វើ Pap តេស្ត នៅពេល 2 ឆ្នាំម្តង។ ចំពោះស្រ្តីដែលមានមេរោគ HIV អ្នកត្រូវធ្វើ Pap តេស្ត 6 ខែម្តង។ បើគេរកឃើញថា អ្នកមានកោសិកាខុសពីធម្មតា នោះអ្នកគួរទៅឲ្យពិនិត្យតាមរយៈ colposcopy គឺការពិនិត្យកស្បូនពិសេស។

បើអ្នកចង់បានពត៌មានថែមទៀតអំពីសេវាគាំទ្រផ្សេងៗ សូមអានសៀវភៅពត៌មានឈ្មោះ CONTACTS ដែលជាមគ្គុទ្ទេសក៍សំរាប់ជនដែលមានជម្ងឺ AIDS ឬ HIV ដែលមានចែកជូនពីសេវា People Living With HIV/AIDS (NSW) តាមទូរស័ព្ទលេខ (02) 9361 6750 ។

**ដើម្បីទទួលពត៌មានស្តីអំពីការព្យាបាល សូមអានប័ណ្ណពត៌មានស្តីពីការព្យាបាល ដែលមានផ្សាយតាមលំដាប់គ្នានេះដែរ។**

**លេខទូរស័ព្ទទាំងនេះត្រឹមត្រូវនៅពេលបោះពុម្ភ ក៏ប៉ុន្តែអាចមិនបានកែតម្រូវតាមការលះទេសៈ។ លោក-អ្នក ប្រហែ អាចត្រូវមើលបញ្ជាក់លេខនៅក្នុង“សៀវភៅទូរស័ព្ទ” (Telephone Directory)។**